ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៥៨៨ សហវ-ប្រក

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ មិថុនា ឆ្នាំ២០១៣

# ប្រកាស

## ស្តីពី

## ការផ្ទេរមុខងារបន្ថែមឱ្យទៅ អង្គភាពគ្រប់គ្រងសាច់ប្រាក់ នៃអគ្គនាយកដ្ឋានរតនាគារជាតិ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ០៤អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ ស្តីពីការបំពេញបន្ថែមនិងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីការបំពេញបន្ថែមនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone: 855-23-724 664 Fax: 855-23-427 798
mef_adm@yahoo.com

- បានឃើញ អនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គ-នាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ ប្រកាស លេខ២១៨ សហវ.ប្រក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការបង្កើតគណៈកម្មាធិការកែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានឃើញប្រកាស លេខ២២៥ សហវ.ប្រក ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៤ ស្តីពីការបង្កើតគណៈកម្មការតាមដានការអនុវត្តន៍ថវិកានិងគ្រប់គ្រងសាច់ប្រាក់
- បានឃើញប្រកាស លេខ៥៩២សហវ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៦ ស្តីពីការកែសំរួលសមាសភាពគណៈកម្មការតាមដានការអនុវត្តថវិកានិងគ្រប់គ្រងសាច់ប្រាក់
- បានឃើញប្រកាស លេខ៦១៥ សហវ.ប្រក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១១ ស្តីពីការផ្ទេរអង្គភាពគ្រប់គ្រងសាច់ប្រាក់ទៅស្ថិតនៅក្នុងអគ្គនាយកដ្ឋានរតនាគារជាតិ
- បានឃើញប្រកាស លេខ១០៧ សហវ.ប្រក.ប ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៣ ស្តីពីការដាក់ប្រើប្រាស់ថវិការង្វាន់នៃចំណូលសារពើពន្ធ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.**

ត្រូវបានផ្ទេរមុខងារលេខាធិការដ្ឋាន នៃគណៈកម្មការតាមដានការអនុវត្តន៍ថវិកា និងគ្រប់គ្រងសាច់ប្រាក់ ដែលត្រូវបានកំណត់ដោយប្រការ១៣ នៃប្រកាសលេខ២២៥ សហវ.ប្រក ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ ២០០៤ ស្តីពីការបង្កើតគណៈកម្មការតាមដានការអនុវត្តន៍ថវិកានិងគ្រប់គ្រងសាច់ប្រាក់ ឱ្យទៅ អង្គភាពគ្រប់គ្រងសាច់ប្រាក់នៃអគ្គនាយកដ្ឋានរតនាគារជាតិ។

**ប្រការ២.**

ត្រូវបាននិរាករសមាសភាពលេខាធិការដ្ឋាន នៃគណៈកម្មការតាមដានការអនុវត្តន៍ថវិកានិងគ្រប់គ្រងសាច់ប្រាក់ ដែលត្រូវបានកំណត់ដោយប្រការ៤ នៃប្រកាសលេខ ៥៩២ សហវ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ ២០០៦ ស្តីពីការកែសំរួលសមាសភាពគណៈកម្មការតាមដានការអនុវត្តន៍ថវិកា និងគ្រប់គ្រងសាច់ប្រាក់។

**ប្រការ៣.**

អង្គភាពគ្រប់គ្រងសាច់ប្រាក់ នៃអគ្គនាយកដ្ឋានរតនាគារជាតិ ត្រូវបានផ្តល់មុខងារបន្ថែមជាលេខាធិ-ការដ្ឋាន នៃគណៈកម្មការតាមដានការអនុវត្តន៍ថវិកានិងគ្រប់គ្រងសាច់ប្រាក់ ក្នុងការគ្រប់គ្រងគណនីថវិកា

រង្វាន់ នៃចំណូលសារពើពន្ធ ដូចមានចែងក្នុងប្រការ១ នៃប្រកាសលេខ ១០៧សហវ.ប្រក.ប ចុះថ្ងៃទី ១៨ ខែមករា ឆ្នាំ២០១៣ ស្តីពីការដាក់ប្រើប្រាស់ថវិការង្វាន់នៃចំណូលសារពើពន្ធ។

**ប្រការ៤.**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គាត ឈន់

**<u>ចម្លងជូន</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ឯកឧត្តមរដ្ឋលេខាធិការ-អនុរដ្ឋលេខាធិការ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ៤ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ